# វានរជាតក



ព្រះសាស្ដាកាលស្ដេចគង់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធការព្យាយាមសម្លាប់ របស់ភិក្ខុទេវទត្ត (មកលើព្រះអង្គ) បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **អសក្ខិំ វត អត្តានំ** ដូច្នេះជាដើម ។

រឿងរ៉ាវ (បច្ចុប្បន្ន) បានពោលពិស្ដារ ក្នុង (**សុសុមារជាតក** ទុកនិបាត) ខាងក្រោយ រួចហើយ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី (ក្នុងកាលនោះ) ព្រះពោធិសត្វកើតក្នុងកំណើតស្វា ក្នុងហិមវន្តប្រទេស កាលចម្រើនវ័យធំហើយ រស់នៅនឹងច្រាំងទន្លេគង្គា ។ ពេលនោះ ក្នុងទន្លេគង្គា មានក្រពើញីមួយកើតចំណង់ប្ញែក (ចង់ស៊ី) សាច់បេះដូងរបស់ព្រះពោធិសត្វ ហើយប្រាប់ដល់ក្រពើឈ្មោល ។

***ក្រពើឈ្មោលគិតថា*** *យើងនឹងចាប់ស្វានោះជ្រមុជក្នុងទឹក សម្លាប់ហើយ យកសាច់បេះដូង ឲ្យដល់ក្រពើញី ដូច្នេះហើយ ក៏ពោលនឹងព្រះមហាសត្វថា នែសម្លាញ់ ចូរមក យើងនឹងទៅបរិភោគផលាផល ដែលនៅនឹងអន្តរទ្វីប* (*ឯណោះ*) ។

***កបិពោធិសត្វពោលថា*** *នែសម្លាញ់ ខ្ញុំនឹងទៅដូចម្ដេចកើត ?*

***ក្រពើពោលថា*** *ខ្ញុំនឹងឲ្យអ្នកអង្គុយលើខ្នងខ្ញុំហើយនាំទៅ ។*

*ព្រះពោធិសត្វកាលមិនដឹងចិត្តក្រពើនោះ ក៏លោតទៅអង្គុយលើខ្នងក្រពើ ។ ក្រពើ* (*នាំ*) *ទៅបានបន្តិច ក៏ប្រារព្ធនឹងជ្រមុជ* (*ព្រះពោធិសត្វ*) ។

***លំដាប់នោះ វានរពោធិសត្វពោលនឹងក្រពើថា*** *នែអ្នកដ៏ចម្រើន ហេតុដូចម្ដេច បានជាអ្នកជ្រមុជខ្ញុំក្នុងទឹក ។*

***សត្វក្រពើពោលថា*** *យើងសម្លាប់អ្នកហើយ យកសាច់បេះដូងឲ្យភរិយារបស់យើង ។*

***ព្រះមហាសត្វពោលថា*** *នែក្រពើល្ងង់ អ្នកសម្គាល់ថា បេះដូងយើងមានក្នុងទ្រូងឬ ?*

***ក្រពើសួរថា*** *បើង តើអ្នកទុកនៅទីណា ?*

***ព្រះពោធិសត្វសួរថា*** *ចុះអ្នកមិនឃើញបេះដូងនោះដែលព្យួរនៅនឹងដើមល្វាទេឬ ?*

***ក្រពើពោលថា*** *ខ្ញុំឃើញ អ្នកចូរឲ្យបេះដូងដល់ខ្ញុំ ។*

***កបិពោធិសត្វពោលថា*** *បាទ ខ្ញុំនឹងឲ្យ ។*

*ក្រពើនោះព្រោះភាពសត្វល្ងង់ខ្លៅ ទើបនាំព្រះពោធិសត្វទៅកាន់ដើមល្វា ដែលនៅប្រាំងទន្លេ ។ ព្រះពោធិសត្វលោតចេញពីខ្នងក្រពើ ទៅអង្គុយលើដើមល្វា ហើយពោលគាថាទាំងឡាយនេះថា*

អសក្ខឹ វត អត្តានំ, ឧទ្ធាតុំ ឧទកា ថលំ;
ន ទានាហំ បុន តុយ្ហំ, វសំ គច្ឆាមិ វារិជ។

*នៃសត្វក្រពើទឹក អញអាចរើខ្លួនអំពីទឹកមកលើគោកហើយ ឥឡូវនេះ អញមិនលុះអំណាចនៃអ្នកឯងទៀតទេ ។*

អលមេតេហិ អម្ពេហិ, ជម្ពូហិ បនសេហិ ច;
យានិ បារំ សមុទ្ទស្ស, វរំ មយ្ហំ ឧទុម្ពរោ។

*ផ្លែឈើទាំងឡាយណា ដែលយើងគប្បីទៅកាន់ត្រើយនៃសមុទ្រ ហើយស៊ី ផ្លែឈើទាំងឡាយនោះ គឺផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ មិនគួរដល់យើងឡើយ ឯផ្លែល្វារបស់យើងទើបប្រសើរជាង ។*

យោ ច ឧប្បតិតំ អត្ថំ, ន ខិប្បមនុពុជ្ឈតិ;
អមិត្តវសមន្វេតិ, បច្ឆា ច អនុតប្បតិ។

*បុគ្គលណា មិនដឹងហេតុដែលកើតឡើងភ្លាម ៗ ទេ បុគ្គលនោះ គង់លុះក្នុងអំណាចសត្រូវផង រមែងក្តៅក្រហាយ ក្នុងកាលជាខាងក្រោយផង ។*

យោ ច ឧប្បតិតំ អត្ថំ, ខិប្បមេវ និពោធតិ;
មុច្ចតេ សត្តុសម្ពាធា, ន ច បច្ឆានុតប្បតិ។

*បុគ្គលណា ដឹងនូវហេតុដែលកើតឡើងភ្លាម បុគ្គលនោះ គង់រួចចាកសេចក្តីចង្អៀត គឺសត្រូវផង មិនក្តៅក្រហាយ ក្នុងកាលជាខាងក្រោយផង ។*

ព្រះមហាសត្វពោលហេតុនៃសេចក្តីសម្រេច របស់កិច្ចការងារក្នុងលោក ដោយគាថា ៤ ដូច្នេះហើយ ក៏ចូលទៅក្នុងព្រៃបានទៅ ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

**តទា សំសុមារោ ទេវទត្តោ អហោសិ** ក្រពើឈ្មោលក្នុងកាលនោះ បានមកជាទេវទត្ត

**វានរោ បន អហមេវ អហោសឹ** បំណែកស្វា គឺ តថាគត នេះឯង ។

វានរជាតក ចប់ ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត ចូឡកុណាលវគ្គ បិដកលេខ ៥៨ ទំព័រ ២៣១)

ថ្ងៃ អាទិត្យ ១៥ កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ២៦ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ.